01204157

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 16 / 02 / 2016
ម៉ោង (Time/Heure): 14:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

002/19-09-2007-ECCC/TC
E1/379

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ពុធ ទី ២០ ខែ មករា ឆ្នាំ ២០១៦

## សវនាការលើភស្តុតាង - ថ្ងៃ ៣៦០

រៀបចំដោយ៖ **ជា ស៊ីវហ៊ាង** និង Evelyn CAMPOS SANCHEZ

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Claudia FENZ, ចៅក្រម យ៉ា សុខន, ចៅក្រម យូរ ឧត្តរា, ចៅក្រម Martin KAROPKIN |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី |
| ក្រឡាបញ្ជី៖ កញ្ញា ជា ស៊ីវហ៊ាង, កញ្ញា Evelyn CAMPOS SANCHEZ |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Nicholas KOUMJIAN, លោក Dale LYSAK, លោក សេង លាង, កញ្ញា សុង ឆវ័ន្ត |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក សុន អរុណ, លោក លីវ សុវណ្ណា |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |

| |
|---|
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោក វ៉ែន ពៅ, លោកស្រី Martine Jacquin, លោកស្រី Marie GUIRAUD, លោកស្រី Chritine MARTINAU |
| សាក្សី៖ សាក្សី 2-TCW-938, ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី (2-TCCP-844) |
| មេធាវីប្រឹក្សា៖ លោក ម៉ម រិទ្ធា |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី សួរ សុធាវី |
| ផ្សេងៗ៖ កញ្ញា សុក សុភ័គមណីកា, លោក វ៉ាត សុម៉ៅ, លោក ឡូញ ង៉ែត, លោក លឿង សូភក្ត័, លោក នូ មនោរ័ត្ន, លោក William McCready |

| <u>ពេលវេលាទូទៅរបស់តុលាការ៖</u> | | |
|---|---|---|
| ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ | ចាប់ផ្តើមម៉ោង៖ ០៩.០៥ | បញ្ចប់ម៉ោង៖ ១៦.០៤ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.១៤ | បញ្ចប់ម៉ោង៖ ១០.៣១ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.៣៥ | បញ្ចប់ម៉ោង៖ ១៣.៣៤ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.៤៣ | បញ្ចប់ម៉ោង៖ ១៥.០១ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ២៥ នាទី |

| <u>កិច្ចដំណើរការនីតិវិធីផ្សេងទៀត</u> | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ ក្រឡាបញ្ជី | ០៩.០៥ | ០៩.០៨ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា | ០៩.០៨ | ០៩.០៩ |
| ការបន្តការតាំងសំណួរទៅកាន់សាក្សី 2-TCW-938 | មេធាវីការពារក្តី នួន ជា | ០៩.០៩<br>១០.៣៣ | ១០.១៤<br>១១.៣៥ |
| សេចក្តីបង្គាប់របស់អង្គជំនុំជម្រះលើការប្រើប្រាស់ប្រតិចារឹកក្នុងអំឡុងពេលសួរដេញដោលសាក្សី 2-TCW-938 | អង្គជំនុំជម្រះ | ១០.៣១ | ១០.៣៣ |

| | | | |
|---|---|---|---|
| ការតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី (2-TCCP-844) | អង្គជំនុំជម្រះ | ១៣.៣៤ | ១៣.៣៩ |
| | មេធាវីដើមបណ្តឹងរដ្ឋប្បវេណី | ១៣.៣៩ | ១៤.៣៤ |
| | សហព្រះរាជអាជ្ញា | ១៤.៣៤ | ១៤.៤២ |
| | | ១៥.០២ | ១៥.២៣ |
| | មេធាវីការពារក្តី នួន ជា | ១៥.២៣ | ១៥.៣៨ |
| | មេធាវីការពារក្តី ខៀវ សំផន | ១៥.៣៨ | ១៦.០២ |

**សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោម សាលសវនាការ។

**សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**ការបន្តការតាំងសំណួរទៅកាន់សាក្សី 2-TCW-938**

មេធាវីការពារក្តី នួន ជា បានតាំងសំណួរទៅកាន់សាក្សី 2-TCW-938 នៅក្នុងសវនាការអសាធារណៈ។

**សេចក្តីបង្គាប់របស់អង្គជំនុំជម្រះលើការប្រើប្រាស់ប្រតិចារឹកក្នុងអំឡុងពេលសួរដេញដោលសាក្សី 2-TCW-938**

អង្គជំនុំជម្រះបានរំលឹកដល់ភាគីអំពីចំណុចពីរ ពាក់ព័ន្ធនឹងការប្រើប្រាស់ប្រតិចារឹកក្នុងអំឡុងពេលសួរដេញដោលសាក្សី។ ទីមួយគឺថា ប្រសិនបើមេធាវីការពារក្តីប្រើប្រាស់ប្រតិចារឹកនៃការផ្តល់សក្ខីកម្មរបស់សាក្សីរូបនោះ គឺមិនអនុញ្ញាតិឱ្យមានការជំទាស់ទេ។ ទីពីរគឺថា ភាគីគួរតែចាប់ផ្តើមសួរសំណួរជាលក្ខណៈទូទៅពាក់ព័ន្ធនឹងចំណេះដឹងរបស់សាក្សី មុននឹងប្រើប្រាស់ប្រតិចារឹក ឬ កំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីផ្សេង ក្នុងការសួរដេញដោលសាក្សីរូបនេះ។

**ការតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី (2-TCCP-844)**

អង្គជំនុំជម្រះ មេធាវីដើមបណ្តឹងរដ្ឋប្បវេណី សហព្រះរាជអាជ្ញា មេធាវីការពារក្តី នួន ជា និង មេធាវី

ការពារក្តី ខៀវ សំផន បានតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី (2-TCW-844) នៅក្នុងសវនាការសាធារណៈ។

## Reclassified

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/9507 | D129/138 | 01056037-01056066 01059269-01059302 01123901-01123925 | Written Record of Interview Witness YOU Vann | P | 01056042-01056043, 01056049-01056050 | 01059275-01059276, 01059283-01059384 | 01123905-01123906, 01123911-01123912 |
| E3/9310 | E305/13/1.3.26 | 00963088-00963154 01064224-01064302 01157154-01157218 | DC Cam Statement of [REDACTED] | P | 00963148 | 01064295 | 01157212 |
| E3/9118 | E305/13.23.405 | 00957771-00957831 01098746-01098786 | Statement of SAO Port (DC-Cam) | P | 00957789 | 01098758 | / |
| E3/9522 | D117/70 | 01046790-01046798 01056213-01056220 01120108-01120115 | Written Record of [REDACTED] | P | 01046797 | 01056219 | 01120114-01120115 |
| E3/9496 | D117/71 | 01046800-01046811 01056221-01056232 01103656-01103667 | Written Record of Interview of [REDACTED] | P | 01046802, 01046809 | 01056223, 01056229 | 01103658, 01103664 |
| E3/6927 | D410/7/1.2.1 | 00633672-00633673 00621411-00621411 | [Corrected 1] Attachment 1: Statement of Successor of LACH Ny (D22/2609), | P | 00633672-00633673 | 00621411-00621411 | / |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | | LACH Kri | | | | |
| E3/5630 | E0/32.2.23 | 00895419-00895423 00678289-00678291 00891890-00891893 | Supplementary statement of LACH Kri ( LACH Kry) | P | 00895419, 00895420 | 00678289, 00678289 | 00891890, 00891991 |
| E3/9340 | D410/7/1.2.3 D166/12 | 00225205-00225208 00233281-00233284 00325248-00325251 | Attachment 3: OCIJ, Written Record of Interview of Witness, LACH Kri, dated 24 September 2008, Doc. no. D166/12 | P | 00225206 | 00233282 | 00325249 |
| E3/5640 | E190.1.57 | 00034380-00034409 00645382-00645407 00657797-00657823 | DC-Cam interview with LACH Kri (Prey Veng district, Prey Veng) | P | 00034406 | 00645404 | 00657820 |

## Other documents (No Change)

| TC No | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/9499 | D129/120 | 01046827-01046845 01063603-01063626 01106528-01106545 | Written Record of Interview of [REDACTED] | C | 01046832-01046834 | 01063610-01063612 | 01106533-01106535 |
| E3/9496 | D117/71 | 01046800-01046811 01056221-01056232 01103656-01103667 | Written Record of Interview of [REDACTED] | C | 01046809 | 01056229 | 01103664 |
| E3/1568 | D313/1.2.406.1 | 00713919-00713993 00651862- | RETYPED from a Handwritten interview of | P | 00713954-00713955 | 00651884 | 00743356 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | 00651907<br>00743328-00743384 | CHEA Sim, Phnom Penh, 3 Dec 1991, and Heng Samrin, Phnom Penh, 2 Dec 1991 | | | | |
| F1/1.1 | / | 01114932-01115255<br>01115129-01115255<br>01117381-01117516 | Transcript of Appeal Proceedings Public Case File N° 002/19-09-2007-ECCC/SC 2 July 2015 | P | / | 01115162-01115172 | 01117417, 01117428 |

**<u>ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖</u>**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៩)
- បង្គាប់កំណត់ពេលវេលារួម សម្រាប់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញាក្នុងការតាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី ឡាច គ្រី (2-TCW-844) ដោយមានពីរវគ្គនៃវគ្គសវនាការ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ៩.00 ព្រឹក នៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៦។ (១៦.០៥)

**<u>កាលវេលាសវនាការបន្ត</u>**

សវនាការនឹងបន្តទៅថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០១៦ ចាប់ផ្ដើមពីម៉ោង ០៩.00 ព្រឹក។

ភ្នំពេញ ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦

ក្រឡាបញ្ជី ក្រឡាបញ្ជី

**ជា ស៊ីវ** ...yn CAMPOS SANCHEZ